ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.......................................................

# សុន្ទរកថាអបអរសាទរ
# លោកជំទាវ ជា សិរី
# អគ្គនាយកបច្ចេកទេស ធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងកម្មវិធីបញ្ចុះបឋមសិលាសាងសង់អាគារបន្ថែមនៃមជ្ឈមណ្ឌលបណ្ដុះបណ្ដាល វិជ្ជាជីវៈតម្បាញសូត្ររបស់ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី

ខេត្តតាកែវ ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៨

**សូមគោរព ៖**

- *លោកជំទាវ ច័ន្ទ សុរិយ៍ រដ្ឋលេខាធិការនៃក្រសួងកិច្ចការនារី*
- *En. Mohd Rizam Razman រដ្ឋលេខាធិការទី១ ស្ថានទូតម៉ាឡេស៊ីប្រចាំនៅកម្ពុជា*
- *លោកស្រី ងន វណ្ណថា ស្ថាបនិក អង្គការសូត្រពណ៌ កម្ពុជា*
- *Dato Johan Ariffin ប្រធានក្រុមប្រឹក្សាភិបាល ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី*
- *Dato Mohd Hanif Suadi នាយកប្រតិបត្តិ ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី*
- *En Shahril Azuar Jimin នាយកប្រតិបត្តិ មូលនិធិធនាគារ មេយប៊ែង*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី និងភ្ញៀវកិត្តិយសទាំងអស់ ដែលមានវត្តមាននៅទីនេះ!*

ថ្ងៃនេះ តាងនាមធនាគារជាតិនៃកម្ពុជា ខ្ញុំមានសេចក្ដីសោមនស្សរីករាយនិងកិត្តិយសក្រៃលែង ដែលបានចូលរួមក្នុងពិធីបញ្ចុះបឋមសិលាសាងសង់អាគារបន្ថែមនៃមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ តម្បាញសូត្ររបស់ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី ដែលប្រារព្ធឡើងនៅខេត្តតាកែវ។ ខ្ញុំសូមសំដែងនូវការអបអរសាទរចំពោះសមិទ្ធផលនាពេលនេះនិងរយៈពេលកន្លងមក និងសូមធ្វើការកោតសរសើរចំពោះថ្នាក់ដឹកនាំរបស់ធនាគារ មេយប៊ែង (ខេមបូឌា) ដែលតែងតែយកចិត្តទុកដាក់ខ្ពស់ក្នុងការចូលរួមចំណែកលើកស្ទួយសេដ្ឋកិច្ច និងសង្គម តាមរយៈការបង្កើតកម្មវិធីនានាដូចជា ការដាក់ឱ្យដំណើរការកម្មវិធីបញ្ញាបចំណេះដឹងផ្នែកហិរញ្ញវត្ថុ Cashville Kidz ដែលជាការរួមចំណែកកសាងធនធានមនុស្សនៅកម្ពុជា ជាពិសេសកុមារដែលជាទំពាំងស្នងឬស្សីឱ្យយល់ដឹងអំពីចំណេះដឹងផ្នែកហិរញ្ញវត្ថុចាប់ពីកុមារភាព ដើម្បីជួយឱ្យពួកគាត់អាចយល់ដឹងពីការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការបានត្រឹមត្រូវ ព្រមទាំងការបង្កើតមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈតម្បាញសូត្រ ដែលជាការរួមចំណែកក្នុងការផ្ដល់ចំណេះដឹង និងជំនាញដល់ស្ត្រីនៅក្នុងសហគមន៍។



ប្រអប់សំបុត្រលេខ ២៥, ឡូតិ៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ឯកឧត្តម លោកជំទាវ លោក លោកស្រីជាទីមេត្រី!**

សព្វថ្ងៃនេះ ស្ត្រីមានសិទ្ធិសេរីភាពស្មើនឹងបុរស ហើយការចូលរួមរបស់ស្ត្រីនៅក្នុងសេដ្ឋកិច្ច កាន់តែមានភាពសកម្មនិងមាននៅគ្រប់វិស័យ។ ស្ត្រីមិនមែនចេះតែការងារផ្ទះនោះទេ តែពួកគាត់មានសមត្ថភាពក្នុងការស្វែងរកចំណូលដើម្បីជួយផ្គត់ផ្គង់ជីវភាពគ្រួសារផងដែរ។ ជាក់ស្តែង ៧០-៨០% នៃការចំណាយរបស់អ្នកប្រើប្រាស់ទាំងអស់នៅលើពិភពលោក គឺមានប្រភពពីស្ត្រី ដូច្នេះស្ត្រីគឺជាផ្នែកមួយដ៏សំខាន់នៃសេដ្ឋកិច្ចពិភពលោក ដោយសារការចំណាយរបស់ស្ត្រីបានជួយជំរុញឱ្យមានកំណើនសេដ្ឋកិច្ច។ យ៉ាងណាមិញ ការចំណាយក៏ត្រូវមានភាពស្មើគ្នានឹងចំណូលផងដែរ ដូច្នេះដើម្បីបន្តជំរុញកំណើនសេដ្ឋកិច្ច យើងចូលរួមលើកកម្ពស់សិទ្ធិសេរីភាពរបស់ស្ត្រីក្នុងការទទួលបានចំណេះដឹង និងជំនាញច្បាស់លាស់ ដើម្បីឱ្យពួកគាត់មានលទ្ធភាពស្វែងមុខរបរដើម្បីជួយផ្គត់ផ្គង់ជីវភាពគ្រួសារ។ ការវិនិយោគជាមួយស្ត្រីដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចនិងសង្គម គឺជាជម្រើសដ៏ឆ្លាតវៃ ហើយការឱ្យតម្លៃនិងលើកកម្ពស់ស្ត្រីទាមទារឱ្យមានការចូលរួមពីគ្រប់មជ្ឈដ្ឋាន។ ជាក់ស្តែង ការមានជំនាញច្បាស់លាស់នៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ គឺទាមទារឱ្យពួកគាត់មានការយល់ដឹងអំពីចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងមានលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុផ្លូវការផងដែរ។ ខ្ញុំជឿជាក់ថា នៅពេលដែលស្ត្រីមានជំនាញនិងមុខរបរច្បាស់លាស់ មានការអប់រំផ្នែកហិរញ្ញវត្ថុ និងយល់ច្បាស់ថាតើ សេវាហិរញ្ញវត្ថុបង្កើតឡើងដើម្បីអ្វី និងអាចជួយអ្វីដល់ពួកគាត់ខ្លះ? នោះស្ត្រីនឹងអាចមានជីវភាពល្អប្រសើរថែមមួយកម្រិតទៀត។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី!**

ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាណាព្យាបាលវិស័យធនាគារទាំងមូល តែងតែយកចិត្តទុកដាក់ខ្ពស់ក្នុងការបណ្តុះបណ្តាលចំណេះដឹងផ្នែកហិរញ្ញវត្ថុ ក៏ដូចជា បានរៀបចំកម្មវិធីអប់រំផ្នែកហិរញ្ញវត្ថុជាច្រើន ជាពិសេស យុទ្ធនាការ "តោះ! និយាយពីលុយ" ដើម្បីលើកទឹកចិត្តឱ្យប្រជាជនកម្ពុជាទាំងអស់និយាយជាមួយក្រុមគ្រួសារអំពីបញ្ហាលុយ ព្រមទាំងការពារប្រជាពលរដ្ឋពីការកេងបន្លំ តាមរយៈការជ្រើសរើសនិងប្រើប្រាស់សេវាហិរញ្ញវត្ថុបានត្រឹមត្រូវនិងចំគោលដៅ។ ខ្ញុំសូមជម្រាបជូនអង្គពិធីផងដែរពីទិសដៅរបស់ធនាគារជាតិនៃកម្ពុជាក្នុងការកាត់បន្ថយអត្រាស្ត្រីដែលពុំទាន់ទទួលបាននិងប្រើប្រាស់សេវាហិរញ្ញវត្ថុ ពីអត្រា ២៧% មកនៅត្រឹម ១៣% ក្នុងរយៈពេលពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១។

ទន្ទឹមនេះ ឪពុកម្តាយក៏ដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ជាមេរៀនហិរញ្ញវត្ថុដល់កូនៗ តាមរយៈការចាយវាយឱ្យមាន i/-ប្រសិទ្ធភាព ii/-ភាពវៃឆ្លាត និង iii/-បែបសន្សំសំចៃ។ នៅពេលដែលកូនៗរបស់ពួកគេឃើញពីទម្លាប់ល្អរបស់ឪពុកម្តាយពួកគេ ពួកគេនឹងអនុវត្តតាមជាក់ជាមិនខាន។

ម្យ៉ាងវិញទៀត ខ្ញុំសូមគូសបញ្ជាក់ផងដែរអំពីអត្ថន័យនៃបាវចនារបស់ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី គឺ "វិស័យហិរញ្ញវត្ថុប្រកបដោយអារិយភាពដល់មនុស្សជាតិ - Humanizing Financial Services"។ ពាក្យនេះមិនសំដៅដល់ការស្វែងរកប្រាក់ចំណេញអតិបរមាជូនភាគទុនិកនៃធនាគារនោះទេ ប៉ុន្តែសំដៅ

ដល់ការស្វែងរកផលចំណេញជូនសហគមន៍ ក៏ដូចជាសង្គមជាតិទាំងមូល។ ជាការពិតណាស់ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈតម្បាញសូត្ររបស់ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី នេះ គឺជាសក្ខីភាពនៃបាវចនានេះ ដោយធនាគារ មេយប៊ែង បានចូលរួមយ៉ាងសកម្មក្នុងការលើកស្ទួយសេដ្ឋកិច្ច និងសង្គម តាមរយៈការផ្តល់ជំនាញ និងលទ្ធភាពដល់ស្ត្រីនៅក្នុងសហគមន៍ក្នុងការរកចំណូល ដើម្បីអនុញ្ញាតឱ្យពួកគាត់អាចធ្វើការសន្សំនិងវិនិយោគ ដែលអាចជួយសម្រួលជីវភាពរស់នៅរបស់ពួកគាត់។ លើសពីនេះ ការបង្កើនឱកាសទទួលបានសេវាហិរញ្ញវត្ថុ យើងមិនគួរផ្តោតតែលើការបង្កើនឱកាសនោះទេ ប៉ុន្តែយើងក៏ត្រូវផ្តោតការយកចិត្តទុកដាក់លើការផ្តល់ចំណេះដឹងអំពីសេវាហិរញ្ញវត្ថុ ក៏ដូចជាការពង្រឹងជំនាញនិងមុខរបរច្បាស់លាស់ដល់ប្រជាជន សំដៅធានាថាពួកគាត់នឹងអាចមានលទ្ធភាពក្នុងការលើកស្ទួយជីវភាពរស់នៅរបស់ខ្លួន និងសង្គមជាតិទាំងមូល។

ជាថ្មីម្តងទៀត ការសាងសង់ពង្រីកអាគារបន្ថែមនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈតម្បាញសូត្ររបស់ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី នៅខេត្តតាកែវ នឹងបន្តចូលរួមចំណែកយ៉ាងសកម្មក្នុងការផ្តល់ឱកាសដល់បងប្អូនស្ត្រីនៅក្នុងសហគមន៍ដើម្បីទទួលបាននូវ ១/-ចំណេះដឹងនិងជំនាញពិតប្រាកដ និង ២/-បង្កើតឱកាសការងារដើម្បីឱ្យពួកគាត់មានលទ្ធភាពស្វែងរកប្រាក់ចំណូលឱ្យក្លាយជាស្ត្រីដែលអាចរកប្រាក់ចំណូលបានដោយឯករាជ្យ។ ការទទួលបាននូវប្រាក់ចំណូលនេះនឹងអនុញ្ញាតឱ្យស្ត្រីយកទៅផ្គត់ផ្គង់ជីវភាពក្នុងគ្រួសារ ដូចជាលទ្ធភាពបញ្ជូនកូនឱ្យទៅរៀនសូត្របានចប់ចុងចប់ដើម ជាពិសេសការសន្សំនិងការវិនិយោគ។

ជាចុងបញ្ចប់ ខ្ញុំសូមលើកទឹកចិត្តចំពោះស្ត្រីតម្បាញទាំងអស់ឱ្យខិតខំគ្រេងគ្រាប់រៀនសូត្រ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចគ្រួសារ សហគមន៍ និងសង្គមជាតិផងដែរ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ស្ថាប័នទាំងអស់នឹងបន្តចូលរួមចំណែកយ៉ាងសកម្មក្នុងការវិនិយោគលើការផ្តល់ចំណេះដឹង និងជំនាញដល់ស្ត្រី មិនថានៅតាមទីក្រុង និងតាមទីជនបទ។ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះធនាគារ មេយប៊ែង (ខេមបូឌា) ក៏ដូចជាមូលនិធិធនាគារ មេយប៊ែង ដែលតែងតែគាំទ្រដល់សកម្មភាពលើកស្ទួយសេដ្ឋកិច្ច និងសង្គម។

សូមឯកឧត្តម លោកជំទាវ និងមន្ត្រី-បុគ្គលិករបស់ធនាគារទាំងអស់ ព្រមទាំងលោក លោកស្រី និងភ្ញៀវកិត្តិយសទាំងអស់ ដែលមានវត្តមាននៅទីនេះ ជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ!